00343258

លេខ / No: D164/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ឯកសារដើម**
**ORIGINAL DOCUMENT/DOCUMENT ORIGINAL**
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 06 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA ...

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
**CERTIFIED COPY/COPIE CERTIFIÉE CONFORME**
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 24 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA ...

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ ៖ 002/19-09-2007-ECCC-OCIJ**

| | |
|---|---|
| ចំពោះមុខ ៖ | ចៅក្រម យូ ប៊ុនឡេង |
| | ចៅក្រម Marcel LEMONDE |
| កាលបរិច្ឆេទ៖ | ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០០៩ |
| ភាសាដើម៖ | ខ្មែរ /បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# ដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាង ដោះបន្ទុកនៅក្នុងឃ្លាំងទុកឯកសាររួម (SMD/Shared Materials Drive)

**សហព្រះរាជអាជ្ញា**

អ្នកស្រី ជា លាង
លោក Robert Petit

**ជនត្រូវចោទ**

នួន ជា
អៀង ធីរិទ្ធ
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី ឡោ ឈុនធី
គង់ ពិសី ហុង គីមសួន
យុង ផានិត គីម ម៉េងឃី
ម៉ុច សុវណ្ណារី

Philippe CANONNE
Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Silke STUDZINSKY

**មេធាវីការពារក្តី**

សុន អរុណ
Michiel PESTMAN
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana Ellis

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (" អ.វ.ត.ក")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញវិធាន ៥៣ វិធាន ៥៥ និង វិធាន ៥៨ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ("វិធានផ្ទៃក្នុង")

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា អៀង សារី** និង **ជនដទៃ ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ** និង**ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងលើឈ្មោះ **អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើស ដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.

បានឃើញសំណើសុំឱ្យមានកិច្ចស៊ើបសួរដែលបានធ្វើឡើងរួមគ្នាដោយក្រុមមេធាវីការពារក្តី **នួន ជា អៀង សារី** និង **អៀង ធីរិទ្ធ** ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុង SMD ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ (D164)

## ការរំលឹកឡើងវិញអំពីនីតិវិធី និងសេចក្តីសំអាងរបស់ក្រុមមេធាវីការពារក្តី

១. នាថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ គឺពីរថ្ងៃបន្ទាប់ពីការបើកកិច្ចស៊ើបសួរបច្ចុប្បន្ន សហព្រះរាជអាជ្ញាបានបើកឱ្យភាគីទាំងអស់ រួមទាំងសហចៅក្រមស៊ើបអង្កេត អាចមើលបាននូវឯកសារទាំងអស់ ដែលមានទម្រង់ជាអេឡិកត្រូនិក និងដែលគេស្គាល់ឈ្មោះជាភាសាអង់គ្លេសថា "Shared Materials Drive /SMD" ("ឃ្លាំងទុកឯកសាររួម")។

២. ពីមុនឯកសារទាំងនេះ អាចរកបាននៅកន្លែងតំកល់ឯកសារសម្រាប់សាធារណជននានា ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា (“DC-CAM”)។

៣. តាមរយៈពាក្យសុំចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៩ ក្រុមមេធាវីការពារក្តី **អៀង ធីរិទ្ធ អៀង សារី** និង **នួន ជា** (“ក្រុមមេធាវីការពារក្តី”) បានស្នើឱ្យសហចៅក្រមស៊ើបអង្កេតស្វែងរកភស្តុតាង ដោះបន្ទុកដែលមាននៅក្នុង SMD (“សំណើសុំ”)។

៤. នៅក្នុងសំណើរួមនោះ ក្រុមមេធាវីការពារក្តីអះអាង៖

- ថា *“នៅក្នុងកិច្ចប្រជុំរវាងតំណាងរបស់ការិយាល័យសហព្រះរាជអាជ្ញា(ក.ស.ព) ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) និងអង្គភាពគាំពារការពារក្តី កាលពីថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០០៩ មានការលេចឮថា ក.ស.ព បានទទួលឯកសារទាំងនេះនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋមរបស់ខ្លួន ហើយថាពួកគេពុំមានពេលវេលាដើម្បីវិភាគលើឯកសារទាំងនេះ នៅមុនពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន។ ដោយសារតែ ក.ស.ព មិនចង់ឱ្យគេចោទប្រកាន់ពីការលាក់កំបាំងនូវធាតុផ្សំនៃភស្តុតាងដោះបន្ទុក និងដោយសារពួកគេយល់ឃើញថា ឯកសារទាំងនេះពាក់ព័ន្ធនឹងសំណុំរឿង ឥឡូវនេះពួកគេសម្រេចបង្ហាញឯកសារទាំងនេះដល់ចៅក្រម និងភាគីទាំងអស់តាមរយៈបណ្តាញមួយផ្សេងពីសំណុំរឿង។ ទោះបីជា ក.ស.ព មិនដឹងពីអត្ថិភាពនៃភស្តុតាងដោះបន្ទុកក៏ដោយ ក៏ ក.ស.ព បានបញ្ជាក់យ៉ាងច្បាស់ថាពួកគេមិនអាចច្រានចោលនូវលទ្ធភាពដែលមានអត្ថិភាពនៃភស្តុតាងបែបនេះដែរ។ វាប្រាកដណាស់ថា ដោយសារតែមូលហេតុនេះទើប ក.ស.ព “លាតត្រដាង” នូវឯកសារទាំងនេះ”*។ (កថា. ៤)

- ថា *“វិធានផ្ទៃក្នុងមិនបានផ្តល់ច្រកណាមួយដើម្បីលាតត្រដាងភស្តុតាងណាមួយក្រៅពីសំណុំរឿងទេ។ (...) ម៉្យាងទៀតទាំង ក.ស.ព និង ក.ស.ច.ស មិនបានគោរពតាមបទបញ្ញត្តិច្បាប់ ឬ នីតិវិធីណាមួយឡើយ ហើយ SMD ទោះបីជាតាមមធ្យោបាយ*

00343261



*ណាមួយក៏ដោយ ក៏មិនអាចពិចារណាថា បានបំពេញគ្រប់គ្រាន់ ឬត្រឹមត្រូវនូវភារៈកិច្ច ស្របច្បាប់នៃការបង្ហាញភស្តុតាងដែរ។*"(កថា. ១៥)

- ថា *"ការបង្កើត SMD នេះ បានជះឥទ្ធិពលឱ្យមានការផ្ទេរដោយមិនត្រឹមត្រូវនូវបន្ទុក នៃការស្វែងរកភស្តុតាងដោះបន្ទុក"* (កថា. ១៦) និងថា *"ដោយសារថា SMD មានចំនួនច្រើនលើសលប់ និងដោយសារធនធានដែលមេធាវីការពារមានស្រាប់មាន កង្វះខាត នោះមិនអាច ពិចារណាបានថា មេធាវីការពារ "អាចរកបាន" នៅពេលនេះ នូវឯកសារនៅក្នុង SMD តាម មធ្យោបាយច្បាស់លាស់ណាមួយបានឡើយ* (កថា. ២០)"។
- ថា តាមរយៈការបង្កើត SMD *"ក.ស.ព និង ក.ស.ច.ស បានព្យាយាមគេចវេសពីការ ទទួលខុសត្រូវតាមផ្លូវច្បាប់ ក្នុងការស្វែងរកភស្តុតាងដោះបន្ទុកដែលអាចជួយដល់ជន ត្រូវចោទ"*(កថា. ២០)។

៥. អាស្រ័យហេតុនេះ មេធាវីការពារក្តី សូមស្នើសហចៅក្រមស៊ើបអង្កេត៖

- *"ពិនិត្យឯកសារទាំងអស់ដែលដាក់នៅក្នុង SMD ដោយ ក.ស.ព ឬ ក.ស.ច.ស"*

- និង *"បង្កើតរបាយការណ៍លំអិតឱ្យបានគ្រប់គ្រាន់ទាក់ទងនឹងការវិភាគរបស់ខ្លួនឱ្យមេ ធាវីការពារដើម្បីធានាថា កិច្ចស៊ើបសួរចាំបាច់ទាំងអស់ត្រូវបានបំពេញដើម្បីកំណត់ ភស្តុតាង ដោះបន្ទុកដែលមានសក្តានុពលភាព"*(កថា. ២៥)។

## សំអាងហេតុនៃសេចក្តីសម្រេច

៦. ដោយអនុវត្តទៅតាមគោលការណ៍នៃការស្វែងរកភស្តុតាងដោយសេរីនៅក្នុងរឿងក្តី ព្រហ្មទណ្ឌ ដែលអនុវត្តនៅមុខ អ.វ.ត.ក. រាល់គម្រុយទាំងអស់ នៅចុងបញ្ចប់អាចក្លាយទៅជា ភស្តុតាង[1]។ ប៉ុន្តែ សូម្បីតែករណីបទល្មើសដាច់ដោយឡែកមួយ ដែលបានប្រព្រឹត្តនៅទីកន្លែងមួយ

---

[1] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក

និងនៅពេលណាមួយជាកំណត់ក៏ដោយ ក៏ជាក់ស្តែងវាមិនអាចប្រមូលគ្រប់តម្រុយទាំងអស់បានដែរ។ វាក៏ដូចគ្នាដែរចំពោះក្របខ័ណ្ឌនៃកិច្ចស៊ើបសួរលើបទឧក្រិដ្ឋដែលមានទំហំធំ ដូចករណីដែលបានប្រព្រឹត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះ ជាការពិតណាស់ ទោះបីជាសហចៅក្រមស៊ើបអង្កេត មិនត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសទៅតាមទំនើងចិត្តរបស់ខ្លួននូវផ្នែកណាមួយនៃតម្រុយដែលប្រមូលបាន និងលាក់ទុកនូវភស្តុតាងមួយចំនួនក៏ដោយ ដូចគ្នាដែរសហចៅក្រមក៏មិនត្រូវធានាថាមានភស្តុតាងទាំងអស់បានដែរ ព្រោះវាជារឿងដែលមិនអាចធ្វើបាន។ ហេតុផលសំខាន់ដែលគ្រប់គ្រងការស៊ើបអង្កេតក្នុងរឿងក្តីព្រហ្មទណ្ឌ គឺគោលការណ៍គ្រប់គ្រាន់នៃភស្តុតាងមានប្រៀបលើគោលការណ៍មានភស្តុតាងទាំងអស់។ កិច្ចស៊ើបសួរអាចបញ្ចប់បាននៅពេលដែលចៅក្រមស៊ើបអង្កេតសំដែងការជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនជាប់ចោទ[2]។ បន្ថែមពីនេះ ការបដិសេធចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរមួយ មិនផ្ទុយនឹងភាពមានអនាគតិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបំពេញការងារស្វែងរកភស្តុតាងទេ[3]។

៧. ដូច្នេះ សម្រាប់ការអនុវត្តន៍ជាក់ស្តែង គឺនៅពេលដែលមានតម្រុយយ៉ាងច្រើនលើសលប់ សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើការការជ្រើសរើស។ ប៉ុន្តែការជ្រើសរើសនេះ មិនត្រូវធ្វើឡើងតាមរយៈការទាត់ចោលនូវតម្រុយមួយចំនួន និងយកជាបានការនូវតែតម្រុយមួយចំនួនផ្សេងនោះទេ៖ យុត្តិកម្មនៃការជ្រើសរើសនេះ គឺស្ថិតនៅត្រង់ថា តម្រុយដែលបានទាត់ចោលមិនបានចូលរួមចំណែកក្នុងការបង្ហាញការពិតច្រើនជាងតម្រុយទាំងឡាយដែលត្រូវបានជ្រើសរើសយក និងដែលតម្រុយនេះ ជាចុងក្រោយ ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង។ ហេតុដូច្នេះហើយការឆ្លើយតបចំពោះសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរមួយ តែងតែត្រូវបានពិនិត្យពិច័យយ៉ាងហ្មត់ចត់ដោយអព្យាក្រឹត ដើម្បីអាចផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ និងច្បាស់លាស់នៃសំណើសុំនេះ។

---

[2] ការជ្រើសមធ្យោបាយដើម្បីបង្ហាញពីការពិត គឺជាឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។ នៅពេលដែលសហចៅក្រមប្រើឆន្ទានុសិទ្ធិនេះ កិច្ចស៊ើបសួរនេះ ត្រូវដែលបានធ្វើដើម្បី *"ដាក់បន្ទុកផង និងដោះបន្ទុកផង"*។ *វិធាន ៥៥(៥)៖ (...) សហចៅក្រមស៊ើបអង្កេតអាចវិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត (...)*។

[3] *"...តាមធម្មជាតិ ដំណើរការដែលប្រព្រឹត្តទៅ ដឹកនាំដោយសហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកការពិតដោយអនាគតិ។"* សូមអាន A193 ទំ. ២។

00343263



៨. សំណើសុំធ្វើឡើងដោយមេធាវីការពារក្តី នឹងមិនត្រូវបានវិនិច្ឆ័យថាត្រឹមត្រូវទេ ប្រសិនបើវាមានគោលបំណងតែមួយគត់ គឺប្រាថ្នាឱ្យស្វែងរកភស្តុតាងទាំងអស់។ ក្នុងរឿងនេះ វាច្បាស់ណាស់ថា មេធាវីការពារក្តី បានធ្វើសំណើសុំដែលមានគោលដៅតែមួយគត់គឺ ពន្លាតបញ្ជីតម្រុយ និងចំនួននៃភស្តុតាង ទោះបីជាព័ត៌មានដែលបានស្នើសុំនោះ មិនបានធ្វើឱ្យការបង្ហាញការពិតមានលក្ខណៈប្រសើរជាងមុនក៏ដោយ។

៩. សំណើសុំនេះ ក៏មិនបានបំពេញលក្ខខណ្ឌទាមទារឱ្យមានភាពច្បាស់លាស់ដែរ ព្រោះវាបានស្នើសហចៅក្រមស៊ើបអង្កេតឱ្យ "ពិនិត្យមើល*ឯកសារទាំងអស់* ដែលដាក់នៅក្នុង SMD"[4]។ ក្រៅតែលក្ខខណ្ឌទម្រង់សុទ្ធសាធ ដែលអាចត្រូវបានបកស្រាយដោយសេរី ការទាមទារឱ្យមានភាពច្បាស់លាស់នៃសំណើសុំ គឺជាកត្តាសំខាន់បំផុត បើសិនជាវាមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងគោលការណ៍ពន្លឿននីតិវិធី និងការបដិសេធចំពោះសំណើទាំងឡាយណាដែលមិនច្បាស់លាស់។ ក្នុងករណីនេះ ការឆ្លើយតបជាវិជ្ជមានចំពោះសំណើសុំមួយដែលមានភាពមិនច្បាស់លាស់ ប្រាកដជាធ្វើឱ្យនីតិវិធីមានការយឺតយ៉ាវ និងដោយមិនត្រឹមត្រូវ ដូច្នេះវាផ្ទុយនឹងគោលការណ៍នៃថិរវេលាមួយសមស្រប។

១០. ការគោរពគោលការណ៍នៃថិរវេលាមួយសមស្រប ឬមានន័យថា ជាការបដិសេធចំពោះរាល់ការពន្យាពេលហួសហេតុ នៅពេលបច្ចុប្បន្នបានក្លាយជាភាពចាំបាច់ដែលមិនអាចខ្វះបានសម្រាប់ធ្វើឱ្យដំណើរនីតិវិធីមានភាពយុត្តិធម៌ និងបានទទួលស្គាល់ដោយអត្ថបទច្បាប់អន្តរជាតិ ហើយដែលមានមួយចំនួនមានអានុភាពផ្ទាល់នៅក្នុងច្បាប់កម្ពុជា[5]។ ថិរវេលា ដែលត្រូវអនុវត្តទាំងនៅយុត្តាធិការជំនុំជម្រះ និងយុត្តាធិការស៊ើបសួរ ត្រូវពិនិត្យមួយករណីម្តងៗ ដូចមានបញ្ជាក់

---

[4] សំណើសុំរបស់មេធាវីការពារក្តី កថា. ២៥ (1)។

[5] មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិ ចុះថ្ងៃទី ១៩ ខែធ្នូ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលកម្ពុជាជាសមាជិក ចែងថា៖

*"ជនត្រូវចោទពីបទល្មើសព្រហ្មទណ្ឌទាំងអស់ មានសិទ្ធិ ដោយស្មើភាពគ្នា យ៉ាងហោចណាស់នូវធានាដូចតទៅ៖ (...)*

*គ) ទទួលបានការជំនុំជម្រះ ដោយមិនមានការពន្យារពេលហួសហេតុ (...)"*

យើងក៏រំលឹកផងដែរថា វិធាន ៨៧(៣)(ខ) នៃវិធានផ្ទៃក្នុង ក៏មានចែងរបៀបដូចគ្នាដែរ។ ចំពោះការអនុវត្តន៍ជាក់ស្តែងនៃវិធាននេះ សូមអានកថាខណ្ឌ ២០ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៩ (E43/4)។

នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ[6]។ ចេញពីនេះសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវដាក់កំហិតពេលវេលាជាក់លាក់មួយ បើហួសពីនេះ ខ្លួនមុខជានឹងធ្វើឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃដំណើរការកាត់ក្តី ហេតុដូច្នេះខ្លួនមានសិទ្ធិ ឬក៏អាចថាមានកាតព្វកិច្ច ទាត់ចោលនូវសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់ភាគីទាំងឡាយណាដែលខ្លួនវិនិច្ឆ័យឃើញថាវាមិនមានប្រយោជន៍ដល់ការបង្ហាញការពិត។

១១. ទឡ្ហីករណ៍របស់មេធាវីការពារក្តី បានលើកឡើងពីកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ដែលក្នុងនោះមាន *"ដោយធានាថារាល់តម្រុយសម្រាប់ដោះបន្ទុកសមហេតុសមផលទាំងអស់ត្រូវបានស្វែងរក"* ដោយមិនមានការចង្អុលបង្ហាញអ្វីផ្សេងទៀតនោះ វាផ្ទុយនឹងលក្ខខណ្ឌទាមទារឱ្យមានភាពត្រឹមត្រូវ និងច្បាស់លាស់ដូចដែលបានរៀបរាប់ខាងលើ៖ មេធាវីការពារក្តីដែលស្នើសុំឱ្យមានកិច្ចស៊ើបសួរមួយ ត្រូវមានកាតព្វកិច្ចពន្យល់ដល់ចៅក្រម តើអ្វីទៅ "ភាពសមហេតុសមផល" នោះ។ ប៉ុន្តែក្នុងរឿងនេះ មិនមានការពន្យល់បែបនេះទេ។

១២. ម្យ៉ាងទៀត ក្រៅពីរឿងខុសប្រព័ន្ធគ្នា វាមិនមែនជាការគ្មានប្រយោជន៍ដែលកត់សំគាល់ថា នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ មេធាវីការពារក្តីត្រូវស្ថិតនៅក្រោមកាតព្វកិច្ចផ្តល់ជូនឯកសារគាំទ្រចំពោះសំណើសុំរបស់ខ្លួន ដើម្បីបង្ហាញពីភាពត្រឹមត្រូវ និងភាពច្បាស់លាស់នៃសំណើសុំរបស់ខ្លួន[7]។

---

[6] មាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុប ស្តីពីសិទ្ធិមនុស្ស ចែងថា *"បុគ្គលទាំងឡាយដែលត្រូវបានឃាត់ខ្លួន ឬជាប់ឃុំ ទៅតាមលក្ខខណ្ឌ ដូចមានចែងនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ត្រូវទទួលបានការជំនុំជម្រះឲ្យបានឆាប់ដោយចៅក្រម ឬដោយមន្ត្រីតុលាការណាដែលទទួលបានសម្បទានដោយច្បាប់ឲ្យបំពេញមុខងារផ្នែកយុត្តាធិការ និងមានសិទ្ធិទទួលបានការជំនុំជម្រះក្នុងថិរវេលាមួយសមស្រប ..."។ ជាច្រើនលើកច្រើនសារ តុលាការក្រុង ស្ត្រាស្ប៊ួរ បានអះអាងថា ថិរវេលាសមស្របចាប់ផ្តើមគិតចាប់តាំងពីពេលដែលជនម្នាក់បានក្លាយជាជនជាប់ចោទ។* ក្នុងរឿងនេះ សូមអានសាលដីកា *Zanouti* ទល់នឹង ប្រទេសបារាំង ថ្ងៃទី ៣១/០៧/២០០១។ សាលដីកា *Ottomani* ទល់នឹង ប្រទេសបារាំង ថ្ងៃទី ១៥/១០/២០០២។ សាលដីកា *Donsimoni* ទល់នឹង ប្រទេសបារាំង ថ្ងៃទី ០៥/១០/១៩៩៩។ សាលដីកា *Etcheveste និង Bidart* ទល់នឹង ប្រទេសបារាំង ថ្ងៃទី ២១/០៣/២០០២។

[7] ក្នុងន័យនេះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីពិចារណាឃើញ ថា៖ *"វាជាកាតព្វកិច្ចរបស់ក្រុមមេធាវីការពារក្តី ដែលត្រូវផ្តល់ជូនតុលាការនូវភស្តុតាងដោះបន្ទុកបឋម ដែលទាក់ទងទៅនឹងអង្គហេតុដែលពាក់ព័ន្ធនានា និងមុនពេលការឃុំខ្លួនដោយរដ្ឋអាជ្ញា"* (សូមមើល ICTY, *Blaskic ២៧ មករា ១៩៩៧ កថាខណ្ឌ ៤៩*)។ ក្នុងករណីដូចគ្នានេះ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៅរ៉្វាន់ដាបានបញ្ជាក់ថា

១៣. នៅក្នុងប្រព័ន្ធដែលមានជាធរមាន នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ សំណើសុំឯកសារដែលស្ថិតក្រោមការកាន់កាប់របស់រដ្ឋអាជ្ញា មានគោលដៅអនុញ្ញាតឱ្យមេធាវីការពារក្តីទទួលបាននូវព័ត៌មានដែលត្រូវការ ដើម្បីវាយតម្លៃពីផលប្រយោជន៍នៃឯកសារទាំងនោះសម្រាប់ការពារកូនក្តីរបស់ខ្លួន។ ប៉ុន្តែសម្រាប់រឿងនេះវិញ ឯកសារទាំងអស់ដែលមាននៅក្នុង SMD ត្រូវបានដាក់ឱ្យភាគីប្រើប្រាស់រួចហើយនៅតាមកន្លែងរក្សាឯកសារនានាដូចជារបស់ DC-Cam ឬក៏នៅក្នុងកម្រងឯកសារសាធារណៈអេឡិកត្រូនិករបស់អង្គការសហប្រជាជាតិ។ ដូចគ្នាដែរ ករណីដែលសហព្រះអាជ្ញាដាក់ឯកសារដែលមកពីប្រភពដែលលើកឡើងខាងលើទៅក្នុង SMD នឹងមិនត្រូវបានបកស្រាយដោយចាត់ទុកថាជា "ការលាតត្រដាង"[8] នោះទេ។ ទស្សនៈ "លាតត្រដាង" មិនអនុវត្តដូចគ្នាទេនៅក្នុងក្របខណ្ឌប្រព័ន្ធរ៉ូម៉ាំងអាល្លឺម៉ង់[9]។ សហព្រះរាជអាជ្ញា

---

នៅពេលដែលមេធាវីការពារក្តី តវ៉ាអំពីការមិនលាតត្រដាង ពីភស្តុតាងដោះបន្ទុក ដោយរដ្ឋអាជ្ញា នោះវាជាការមិនគ្រប់គ្រាន់ដែលមេធាវីយោងទៅដល់ឯកសារទាំងនេះថា *"វាដូចជាឯកសារ "ត្រឹមត្រូវ" សម្រាប់រឿងក្តីរបស់ខ្លួន និង "ចាំបាច់សម្រាប់មេធាវី" និងគ្រាន់តែអះអាងថាវា "មានឯកសារដោះបន្ទុក" ដោយមិនមានការពន្យល់លើសពីនេះ ហេតុអ្វីបានជាវាអាច "បិទសំណុំរឿង" ឬសម្រាលការទទួលខុសត្រូវផ្ទាល់ខ្លួន"*៖ ICTR, *Ferdinand Nahimana និងអ្នកដទៃ ទល់នឹង រដ្ឋអាជ្ញា* សាលាឧទ្ធរណ៍ សេចក្តីសម្រេចលើសំណើសុំរបស់ Ferdinand Nahimana ក្នុងគោលបំណងឲ្យលាតត្រដាងពីឯកសារដែលរដ្ឋអាជ្ញាមាន និងចាំបាច់សម្រាប់មេធាវីការពារដើមបណ្តឹងឧទ្ធរណ៍ និងក្នុងគោលបំណងជួយដល់ក្រឡាបញ្ជីក្នុងការបំពេញកិច្ចស៊ើបសួរបន្ថែម នៅក្នុងដំណាក់កាលឧទ្ធរណ៍ ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០០៦ កថា. ៨ និងនៅក្នុងសេចក្តីសម្រេច ក្នុងរឿងជំទាស់នឹងការការលាតត្រដាងដោយរដ្ឋអាជ្ញា៖ *"នៅពេលដែលមេធាវីយល់ឃើញថា មានការរំលោភលើមាត្រា ៦៨ នៃវិធាន កើតមានឡើង ខ្លួនត្រូវដាក់ជូនអង្គជំនុំជម្រះ នូវភស្តុតាងតាំងពីដំបូងដែលទំនងជាភស្តុតាងមានលក្ខណៈដោះបន្ទុក ព្រមទាំងការរក្សាទុកឯកសារទាំងនេះដោយរដ្ឋអាជ្ញា"* (កថា. ៧)។

[8] ជាពិសេស ការបង្កើត SMD មិនបង្ហាញថាជា ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញា ក្នុងការ "កប់ចោល" ភស្តុតាងដោះបន្ទុកទេ ឬក៏គេចពីការទទួលខុសត្រូវរបស់ខ្លួនលើបញ្ហាលាតត្រដាងដែរ ដូចជាករណីដែលបានសម្រេចដោយតុលាការអឺរ៉ុបស្តីពីសិទ្ធិមនុស្ស៖ ICTR, ព្រះរាជអាជ្ញាទល់នឹង *Karamera និងអ្នកដទៃ* សាលាឧទ្ធរណ៍ សេចក្តីសម្រេច លើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងតួនាទីការលាតត្រដាងអេឡិកត្រូនិករបស់ព្រះរាជអាជ្ញា ក្នុងការធ្វើឲ្យរួចផុតពីកាតព្វកិច្ចលាតត្រដាង ៣០ មិថុនា ឆ្នាំ ២០០៦។

[9] កាតព្វកិច្ចជាវិជ្ជមានរបស់រដ្ឋអាជ្ញាក្នុងការលាតត្រដាងភស្តុតាងដោះបន្ទុក ដែលខ្លួនមាន ដោយផ្អែកលើវិធានរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ (TPIY វិធាន ៧០ TPIR វិធាន ៦៨) គឺមានសារៈសំខាន់នៅក្នុងបរិបទនៃប្រព័ន្ធ "Common Law" អាស្រ័យដោយមិនមានសំណុំរឿងស៊ើបអង្កេតធ្វើឡើងដោយចៅក្រមអញ្ញាក្រឹត។ ហេតុដូច្នេះ Electronic Disclosure Suite (EDS) នៅ TPIR មានធាតុភស្តុតាងដែល *ដែលត្រូវបានវិភាគរួចហើយ* ដោយរដ្ឋអាជ្ញា និងត្រូវបានជ្រើសរើសដើម្បីដាក់បញ្ចូលយ៉ាងត្រឹមត្រូវទៅតាមប្រភេទរបស់វា រួមទាំងភស្តុតាងនានាដែលអាចជាភស្តុតាងដោះបន្ទុក ទៅតាមខ្លួនដឹង។

ក៏ដូចជាការទទួលស្គាល់របស់មេធាវីការពារក្តី[10] បានបង្ហាញឱ្យដឹងច្បាស់ថា ខ្លួនមិនបានដឹងអំពីវត្តមាននៃភស្តុតាងដោះបន្ទុកនៅក្នុងឯកសារទាំងនេះទេ។ ទោះបីជាហេតុ ដែលថា ពិធីសារពន្យល់ភ្ជាប់ជាមួយ SMD ដោយ CMS (ដែលជាឯកសារមិនផ្លូវការ និងមិនមានតម្លៃគតិយុត្ត) មិនបានទាត់ចោលករណីដែលអាចមានភស្តុតាងទាំងនោះក៏ដោយ ក៏វាមិនធ្វើឱ្យប៉ះពាល់ដល់អះអាងពីដំបូងរបស់សហព្រះរាជអាជ្ញាដែរ។ សហព្រះរាជអាជ្ញា មានកាតព្វកិច្ច ដាក់ចូលទៅក្នុងសំណុំរឿងនូវរាល់ភស្តុតាងដោះបន្ទុកទាំងអស់ *"ដែលខ្លួនបានដឹង"* ហើយវាមានការសន្មតជាមុនថាពួកគេបានធ្វើឡើងដោយសុទ្ធចិត្ត[11]។

១៤. ម្យ៉ាងវិញទៀត កាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ក្នុងការជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត អំពីគ្រប់ភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុក ដែលខ្លួនបានដឹង[12] មិនគួរត្រូវបានបកស្រាយដោយមិនត្រឹមត្រូវនោះទេ។ ការចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នាំមកនូវផលវិបាកពីរយ៉ាងគឺ ទី១ វាជាការផ្តល់សមត្ថកិច្ចលើសំណុំរឿងទៅឱ្យសហចៅក្រមស៊ើបអង្កេត និងទី២ គឺជាការបញ្ឈប់សមត្ថកិច្ចស៊ើបអង្កេតរបស់សហព្រះរាជអាជ្ញា។ ដូច្នេះរាប់ចាប់តាំងពីថ្ងៃ ១៨ កក្កដា ២០០៧ មក សហព្រះរាជអាជ្ញាលែងមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតទៀតហើយ។ ដោយយល់ឃើញថា ឯកសារសាធារណៈមួយចំនួន ដែលខ្លួនមានអាចនឹងមានប្រយោជន៍ដល់ដំណើរការនៃរឿងក្តី សហព្រះរាជអាជ្ញាបានសម្រេចចិត្តផ្តល់ឯកសារទាំងនោះទៅដល់គ្រប់ភាគី ក៏ដូចជាសហចៅក្រមស៊ើបអង្កេតផងដែរ ធ្វើដូច្នេះគឺគោរពតាមស្មារតីនៃគោលការណ៍សមភាព

---

[10] D164 *សំណើសុំបំពេញកិច្ចស៊ើបសួររួមរបស់ក្រុមមេធាវីការពារក្តី ក្នុងការស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម SMD* ថ្ងៃទី ២០ មេសា ២០០៩ កថាខណ្ឌ ០៤។

[11] នៅក្នុងរឿងនេះ យោង ICTR, *Ferdinand Nahimana និងអ្នកដទៃ ទល់នឹង រដ្ឋអាជ្ញា* សាលាឧទ្ធរណ៍ សេចក្តីសម្រេចលើសំណើសុំរបស់ Ferdinand Nahimana ក្នុងគោលបំណងឲ្យលាតត្រដាងពីឯកសារដែលរដ្ឋអាជ្ញាមាន និងចាំបាច់សម្រាប់មេធាវីការពារដើមបណ្តឹងឧទ្ធរណ៍ និងក្នុងគោលបំណងជួយដល់ក្រឡាបញ្ជីក្នុងការបំពេញកិច្ចស៊ើបសួរបន្ថែម នៅក្នុងដំណាក់កាលឧទ្ធរណ៍ ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០០៦ កថា. ៧។

[12] ជាឧទាហរណ៍ យោងតាមវិធាន ៥៣ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ៖ *"២. ដីកានេះត្រូវអមដោយសំណុំរឿង និងសម្ភារៈដទៃទៀតដែលបានចាត់ទុកជាភស្តុតាង ដែលសហព្រះរាជអាជ្ញាមានរួចទាំងអស់ ទាំងអស់ដែលសហព្រះអាជ្ញា**បានដឹង**ថា អាចជាភស្តុតាងដោះបន្ទុកផងដែរ។"* ហើយក្នុងដំណាក់កាលនៃការស៊ើបសួរ *"៤. ក្នុងរយៈពេលឆាប់ដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញាត្រូវបង្ហាញទៅសហចៅក្រមស៊ើបអង្កេត នូវសម្ភារៈ ទាំងឡាយដែលសហព្រះរាជអាជ្ញាបានដឹង ហើយដែលសម្ភារៈទាំងនេះនឹងអាចនាំឲ្យគ្មានពិរុទ្ធភាព ឬសម្រាលពិរុទ្ធ ភាពនៃជនសង្ស័យ ឬជនត្រូវចោទ ឬធ្វើឲ្យប៉ះពាល់ដល់ភាពជឿជាក់នៃភស្តុតាងក្នុងការចោទប្រកាន់។"*

ក្នុងការតទល់ការពារក្តី[13] និងដើម្បីដំណើរការលឿនទៅមុខនៃនីតិវិធី។ ដើម្បីធ្វើដូច្នេះបាន សហព្រះរាជអាជ្ញាមិនចាំបាច់ត្រូវការមូលដ្ឋានគតិយុត្តណាមួយពិសេសនោះទេ។ ដូច្នេះការបង្កើតឱ្យមាន SMD វាមិនមែនជាការប៉ុនប៉ង "លាតត្រដាង" ក្នុងចេតនាទុច្ចរិត ដូចដែលបានអះអាងដោយក្រុមមេធាវីការពារក្តីនោះទេ ហើយទង្វើនេះ វាក៏មិនប៉ះពាល់ដល់កាតព្វកិច្ចរបស់ភាគីផ្សេងទៀតនៃកិច្ចស៊ើបសួរនោះដែរ។ សូមធ្វើការរំលឹកថា ភាគីនៅតែមានសិទ្ធិ និងសេរីភាពពេញលេញក្នុងការអានគ្រប់ឯកសារទាំងអស់ ដែលទទួលបានពីគ្រប់ប្រភពជាសាធារណៈទាំងអស់ ដើម្បីសិក្សា និងវិភាគស្វែងរកភស្តុតាង ហើយក្នុងករណីខ្លះ ក៏អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿងផងដែរ។ ការស្វែងរកឯកសារជាលក្ខណៈបឋមទាំងនេះ វាមិនប៉ះពាល់ដល់គោលការណ៍នៃការហាមឃាត់មិនឱ្យភាគីបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងនោះទេ[14]។ សរុបសេចក្តីមក ដោយយោងលើចំណុចពិសេសនៃដំណើរការរឿងក្តីព្រហ្មទណ្ឌអន្តរជាតិក្នុងបរិបទកម្ពុជា តួយ៉ាងដូចជាប្រភពធនធានឯកសារដ៏ធំធេង SMD គឺជាមធ្យោបាយផ្នែកបច្ចេកទេសមួយដ៏ពិសេសសម្រាប់បម្រើឱ្យគ្រប់អង្គភាពទាំងអស់របស់ អ.វ.ត.ក ហើយដែលមធ្យោបាយនេះមិនបង្កឱ្យមានជាព្យសនកម្មអ្វីប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមមេធាវីការពារក្តីនោះទេ[15]។

១៥. ជាលទ្ធផល ការសិក្សាវិភាគបានផ្តល់នូវកំណត់សម្គាល់ដូចខាងក្រោម៖

---

[13] ដោយសារថា សហព្រះរាជអាជ្ញាបានទទួលកម្រងឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាជាទំរង់អេឡិកត្រូនិក ធ្វើ ឲ្យសហព្រះរាជអាជ្ញាអាចមានលទ្ធភាពច្រើនជាងក្នុងការចូលមើលឯកសារទាំងនោះ លើទិដ្ឋភាពបច្ចេកទេស បើប្រៀបធៀបនឹងភាគីដ៏ទៃទៀត។ ដូច្នេះការបញ្ជូនឯកសារទាំងនោះទៅអង្គភាពគ្រប់គ្រងតុលាការ វាសម្រួលឲ្យការចូលមើលឯកសារទាំងនោះអាចធ្វើឡើងដោយស្មើភាពគ្នា ពីគ្រប់ភាគីទាំងអស់។

[14] ទាក់ទងនឹងបញ្ហានេះ សូមមើល អនុស្សរណៈរបស់សហចៅក្រមស៊ើបសង្កេត ចំពោះក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ១០ មករា ២០០៨ (A110/I)។

[15] ជាក់ស្តែង ការបញ្ចូលឯកសារថតចម្លងអេឡិកត្រូនិកទៅក្នុង Zylab អនុញ្ញាតជាពិសេសឲ្យមានការស្វែងរកឯកសារតាមរយៈពាក្យគន្លឹះ និងឆាប់រហ័ស ទៅលើខ្លឹមសារទាំងមូលនៃអត្ថបទ និងថែមទាំងអាចឲ្យធ្វើការចម្រាញ់យកប្រភព ដែលចង់បានផងដែរ។ នៅពេល ដែលឯកសារត្រូវបានរកឃើញរួចហើយ យើងអាចយកឯកសារនោះដោយងាយស្រួលតាមរយៈទំរង់ "pdf" និងថែមទាំងអាចចម្លងចេញក្នុងទំរង់ជាអត្ថបទ ដើម្បីដាក់បញ្ចូលក្នុងឯកសារមួយផ្សេងទៀត។ ការដាក់លេខ ERN នៅលើទំព័រនីមួយៗ អាចអនុញ្ញាតឲ្យយើងអាចយោងលើឯកសារនោះ ដោយងាយស្រួល ឬអាចងាយស្រួលក្នុងការដាក់បញ្ចូលទៅក្នុងសំណុំរឿង ដោយសហចៅក្រមស៊ើបអង្កេត។

- រាល់ពេលដែលសហចៅក្រមស៊ើបអង្កេតត្រូវបំពេញកិច្ចស៊ើបសួរ ដែលតម្រូវឲ្យមានការស្វែងរកភស្តុតាងជាឯកសារ ដែលមានប្រយោជន៍ដល់ការបង្ហាញការពិត ដែលអាចធ្វើឡើងក្រោមសំណើរបស់ភាគី ឬដោយគំនិតផ្តួចផ្តើមផ្ទាល់ក៏ដោយ សហចៅក្រមស៊ើបអង្កេតអាចពិនិត្យលើគ្រប់ប្រភពឯកសារទាំងអស់ ដែលខ្លួនយល់ថា មានផ្ទុកនូវឯកសារដែលចង់ស្វែងរក ឧទាហរណ៍ ដូចជាឯកសារដែលមាននៅក្នុង SMD។

- រាល់ឯកសារទាំងអស់ ដែលរកឃើញដោយសហចៅក្រមស៊ើបអង្កេត ឆ្លើយតបទៅនឹង លក្ខណៈវិនិច្ឆ័យទាំងនេះ ដែលអាចជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុក នឹងត្រូវបានដាក់បញ្ចូល ទៅក្នុងសំណុំរឿងជាស្វ័យប្រវត្តិ មានន័យថាគ្រប់ភាគីទាំងអស់អាចចូលមើលឯកសារទាំង នោះបានផងដែរ។

- SMD មិនបំពេញមុខងារដូចកម្រងឯកសារអេឡិកត្រូនិកនៃភស្តុតាងដែលបានវិភាគរួចហើយ ដែលប្រើដោយរដ្ឋអាជ្ញានៃតុលាការអន្តរជាតិផ្សេងៗនោះទេ។ នៅក្នុងក្របខណ្ឌនៃ អ.វ.ត.ក. មុខងារបែបនេះត្រូវបានបំពេញដោយសំណុំរឿងព្រហ្មទណ្ឌ ដែលសហចៅក្រមស៊ើបអង្កេត ជាអ្នកមានសិទ្ធិដាក់បញ្ចូលទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ក្រោមគំនិតផ្តួចផ្តើមផ្ទាល់ ឬតាមសំណើសុំរបស់ភាគី រួមទាំងឯកសារដែលទទួលបានពី SMD ផងដែរ។

- សំណើសុំបំពេញកិច្ចស៊ើបសួរ ដែលមិនបានបង្ហាញអំពីកម្មវត្ថុ និងផលប្រយោជន៍នៃកិច្ចស៊ើបសួរដែលបានស្នើសុំ មិនត្រឹមតែអាចនាំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការជ្រើសរើសឯកសារ ដែលមានទំរង់ជាឯកសារថតចម្លងអេឡិកត្រូនិក ដែលមានក្នុង SMD ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការពិនិត្យលើគ្រប់ប្រភពឯកសារទាំងអស់ដែលអាចមានផងដែរ។ សំណើសុំបែបនេះ មិនបំពេញត្រឹមត្រូវតាមលក្ខខណ្ឌនៃគោលការណ៍គ្រប់គ្រាន់នៃភស្តុតាង និងគោលការណ៍នៃភាពច្បាស់លាស់ ដូចមានបង្ហាញរួចមកហើយនោះទេ[16] ។

---

[16] ICTY *Blaskic* ២៦ កញ្ញា ២០០០ កថាខណ្ឌ ៤០ សេចក្តីសម្រេចស្តីអំពីសំណើសុំរបស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងការថតចម្លើងឯកសារ ការឮរ ឬការបន្តថេរៈវេលាក្នុងការដាក់សារណា និងការដាក់ឯកសារបន្ថែម៖ *"សំណើសុំថតចម្លងឯកសារត្រូវតែមានលក្ខណៈលំអិតគ្រប់គ្រាន់ ដោយបញ្ជាក់អំពីប្រភេទនៃភស្តុតាង ដែលស្វែងរក និងជាអ្វីដែលអ្នក*

- អនុលោមតាមគោលការណ៍គ្រប់គ្រាន់នៃភស្តុតាង និងដើម្បីបំពេញមុខងារអញ្ញាក្រឹត្យរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចក្នុងការស្វែងរកភស្តុតាងដោះបន្ទុក ដោយគ្មានរយៈពេលកំណត់នោះទេ (ដែលជាភាសាអង់គ្លេស ហៅថា "FISHING EXPEDITIONS[17]")។

- សំណើសុំរបស់ក្រុមមេធាវីការពារក្តីឱ្យមានការតាក់តែង "របាយការណ៍លំអិតគ្រប់ជ្រុងជ្រោយ" អំពីខ្លឹមសារ ទិន្នន័យទាំងមូល ដែលមានក្នុង SMD វាប្រៀបបានទៅនឹងសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការពិនិត្យវិភាគលើឯកសារជំនួសពួកគេ និងដែលតាមពិតពួកគេក៏មានលទ្ធភាពក្នុងការចូលមើលឯកសារទាំងនោះផងដែរ។ ហើយមិនត្រឹមតែប៉ុណ្ណោះសំណើសុំនោះ ក្រៅអំពីនិទ្ទេសជាលក្ខណៈទូទៅ ក៏មិនមានបញ្ជាក់អំពីហេតុផល ដែលអាចនាំឱ្យជឿបានថាមានភស្តុតាងដោះបន្ទុកនោះទេ។ ដូច្នេះការតាក់តែងរបាយការណ៍ខាងលើនេះ មិនឋិតនៅក្នុងសមត្ថកិច្ច របស់សហចៅក្រមស៊ើបអង្កេតនោះឡើយ។

- ប្រសិនបើ បន្ទាប់ពីបានធ្វើការស្រាវជ្រាវជាបឋមលើរាល់ខ្លឹមសារទិន្នន័យដែលមាននៅក្នុង SMD ឬប្រភពឯកសារជាសាធារណៈផ្សេងៗទៀតរួចហើយ ក្រុមមេធាវីការពារក្តីទទួលបាន នូវព័ត៌មានភស្តុតាង ដែលខ្លួនចង់ទាញចំណាប់អារម្មណ៍របស់សហចៅក្រមស៊ើបអង្កេត ឬ ឯកសារទាំងឡាយណា ដែលខ្លួនជឿថា មានព័ត៌មានដោះបន្ទុកនោះ ក្រុមមេធាវីការពារក្តី អាចធ្វើការជូនដំណឹងមកយើងអំពីឯកសារទាំងនោះបាន។

---

*ទទួលសំណើមាននៅក្នុងដៃ"*។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូង បានទាមទារឲ្យក្រុមមេធាវីការពារក្តី ធ្វើការបញ្ហាញអំពី "ការសន្មតនៃភាពចាំបាច់" នៃរាល់ភស្តុតាង (សូមមើល ICTY *Delalic* ២៥ មិថុនា ១៩៩៧ សេចក្តីសម្រេចលើសំណើសុំរបស់ជនត្រូវចោទ Hazim Delic ក្នុងការទទួលបាននូវព័ត៌មានដោះបន្ទុក អនុលោមតាមវិធាន ៦៨ កថាខណ្ឌ ១៣ ១៥ និង ១៧។ សូមមើលផងដែរនូវលេខយោងលេខ 7 ខាងលើ។

[17] សូមមើលជាឧទាហរណ៍ *រដ្ឋអាជ្ញា ទល់នឹង Delalic* យោបល់ដាច់ដោយឡែករបស់លោកចៅក្រម David Hunt លើសំណើសុំរបស់ Esad Landzo ក្នុងការថែរក្សា និងការប្រគល់ភស្តុតាង ២២ មេសា ១៩៩៩ កថា.៤។ សូមមើលផងដែរ *រដ្ឋអាជ្ញា ទល់នឹង Hadzihasanovic* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធក្នុងការផ្តល់នូវលទ្ធភាពចូលមើលឯកសារសម្ងាត់នៅក្នុងសំណុំរឿងមួយផ្សេងទៀត ២៣ មេសា ២០០២ ទំ.៣។

## ហេតុដូច្នេះសម្រេច

បដិសេធ សំណើសុំនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

យូ ប៊ុនឡេង

**Marcel LEMONDE**